# ក្រុមប្រឹក្សាសាលា

ក្រុមប្រឹក្សាសាលា (SAC) ត្រូវបានបោះឆ្នោតឲ្យដោយអ្នក នៅក្នុងក្រុម ក្រុមដែលរួមសហការគ្នាដើម្បីបង្កើនជោគជ័យនៃការសិក្សារបស់សិស្ស ការបង្រៀនដែលមានប្រសិទ្ធិភាពនៅក្នុងថ្នាក់រៀន និង ការចូលរួមរបស់ មាតាបិតា និង សហគមន៍ នៅក្នុងវិធីអប់រំ។

## ក្រុមប្រឹក្សាសាលា មានគោលបំណងសំខាន់ៗបី៖



ជួយឲ្យមានជោគជ័យក្នុងការសិក្សា



បង្កើនសុវត្ថិភាពរបស់សាលា



ពង្រឹងការចូលរួមរបស់មាតាបិតា

## តើអ្នកណាខ្លះនៅក្នុងក្រុមប្រឹក្សាសាលា?

ក្រុមប្រឹក្សាសាលា ត្រូវតែរួមបញ្ចូល សមាជិកគ្រួសារ ជាមួយ នាយកសាលា បុគ្គលិក សិស្សានុសិស្ស (នៅសាលាដែលមាន ថ្នាក់ទី៧ ដល់ ទី១២) និង សមាជិកសហគមន៍។ ការបែងចែកអាសនៈគប្បីមានដូចតទៅនេះ៖

### សាលាបឋមសិក្សា
### មានសមាជិកទាំងអស់ ៨ នាក់




### អនុវិទ្យាល័យ/វិទ្យាល័យ
### មានសមាជិកទាំងអស់ ១១នាក់




## តើសមាជិកធ្វើអ្វីខ្លះ?

ជួបប្រជុំរៀងរាល់ខែ (ឬ យ៉ាងហោចណាស់ពីរខែម្តង)។)

ចូលរួមក្នុងការពិភាក្សារកវិធីសាស្ត្រ តាមការប្រើ និងការដោះស្រាយទិន្នន័យសាលា។

ផ្តោតទៅលើ ការជួយឲ្យមានជោគជ័យក្នុងការសិក្សា ការបង្កើនសុវត្ថិភាពរបស់សាលា និង ការពង្រឹងការចូលរួមរបស់មាតាបិតា។

ប្រមូលគំនិតយោបល់ពីសមាជិក នៃក្រុមប្រឹក្សាសាលារបស់លោកអ្នក។

## តើ ក្រុមប្រឹក្សាសាលា ខុសគ្នាពី សមាគមមាតាបិតា និងសាលា មិត្តភ័ក្ត ឬ ក្រុមសហគមន៍ របស់សាលា ផ្សេងទៀត ដូចម្តេចដែរ?

### ក្រុមប្រឹក្សាសាលាមានលក្ខណៈវិនិច្ឆ័យមួយចំនួន ដែលពួកគេត្រូវបំពេញ៖

១. ក្រុមប្រឹក្សាសាលា ត្រូវរួមបញ្ចូលអ្នកសំខាន់ៗទាំងអស់៖ រួមមាន នាយកសាលា មាតាបិតា/សមាជិកក្រុមគ្រួសារ បុគ្គលិកសាលា សមាជិកសហគមន៍ និង សិស្សានុសិស្ស (សម្រាប់តែ អនុវិទ្យាល័យ និង វិទ្យាល័យ តែប៉ុណ្ណោះ)។

២. អង្គប្រជុំរបស់ក្រុមប្រឹក្សាសាលា ត្រូវតែផ្តោតទៅលើការពិភាក្សារកវិធីសាស្ត្រ ជាជាងការរកប្រាក់វិភាគទាន ឬ រៀបចំកម្មវិធីអ្វីមួយ។ ការពិភាក្សារកវិធីសាស្ត្រ តម្រូវឲ្យមានការពិនិត្យទិន្នន័យសាលា និង ការរកដំណោះស្រាយទៅនឹងបញ្ហាដែលប៉ះពាល់ដល់សាលា។ ក្រុមប្រឹក្សាសាលា គឺជាឱកាសសម្រាប់ មាតាបិតា/ក្រុមគ្រួសារ បុគ្គលិក សិស្សានុសិស្ស សមាជិកសហគមន៍ និងនាយកសាលា ដើម្បីសហការគ្នា ដោះស្រាយបញ្ហា និងបង្កើតវិធីសាស្ត្រផ្សេងៗ ដើម្បីពង្រឹងសាលា និង បង្កើនជោគជ័យក្នុងការសិក្សា។

៣. សមាជិកនៃក្រុមប្រឹក្សាសាលា អាចជាសមាជិកនៃ ក្រុមសហគមន៍សាលាផ្សេងទៀត ដូចជា សមាគមមាតាបិតា និងសាលា ឬ មិត្តភ័ក្តនៃក្រុមសហគមន៍របស់សាលា។ នេះគឺជាឱកាសដ៏ល្អសម្រាប់អ្នកសំខាន់ៗ ដើម្បីផ្សាទំនាក់ទំនងជាមួយក្រុមផ្សេងៗទៀត។

## សូមដាក់ពាក្យសុំចូលរួមឥឡូវនេះ តាមវ៉ិបសៃ www.philasd.org/sac